# ពិភពផ្លាស្ទិក

ការពិត និងតួលេខស្តីពី ផ្លាស្ទីករាយពេញផែនដី ឆ្នាំ២០១៩



HEINRICH BÖLL STIFTUNG #breakfreefromplastic

# IMPRINT

The PLASTIC ATLAS 2019 is jointly published by
Heinrich Böll Foundation, Berlin, Germany, and Break Free From Plastic

Executive editors:
Lili Fuhr, Heinrich Böll Foundation
Matthew Franklin, Break Free From Plastic

Managing editor: Kai Schächtele
Art direction and infographics: Janine Sack, Sabine Hecher, Lena Appenzeller
Project management: Kristin Funke, Annette Kraus
English editor: Paul Mundy
Proofreader: Maria Lanman
Research editor: Alice Boit

Contributors: Claire Arkin, David Azoulay, Alexandra Caterbow, Christine Chemnitz, Camille Duran, Marcus Eriksen, Steven Feit, Manuel Fernandez, Chris Flood, Lili Fuhr, Elisabeth Grimberg, Stephan Gürtler, Lea Guerrero, Johanna Hausmann, Von Hernandez, Ulrike Kallee, Christie Keith, Doris Knoblauch, Christoph Lauwigi, Linda Mederake, Doun Moun, Carroll Muffett, Jane Patton, Christian Rehmer, Kai Schächtele, Dorothea Seeger, Olga Speranskaya, Esra Tat, Nadja Ziebarth

The content does not necessarily express the views of all partner organizations involved.

Editorial responsibility (V. i. S. d. P.): Annette Maennel, Heinrich Böll Foundation

First edition, November 2019

ISBN 978-3-86928-211-4

Production manager: Elke Paul, Heinrich Böll Foundation

Printed by Druckhaus Kaufmann, Lahr, Germany
Climate-neutral printing on 100 percent recycled paper

Klimaneutral
Druckprodukt
ClimatePartner.com/11061-1904-1002

FSC
www.fsc.org
RECYCLED
Papier aus Recyclingmaterial
FSC® C002639

Except for the cover photo, this material is licensed under Creative Commons license "Attribution 4.0 International" (CC BY 4.0). For the license agreement, see https://creativecommons.org/licenses/by/4.0/legalcode and for a summary (not a substitute) see https://creativecommons.org/licenses/by/4.0/deed.en. Individual infographics from this atlas may be reproduced if the attribution PLASTIC ATLAS | Appenzeller/Hecher/Sack CC-BY-4.0 is placed next to the graphic (in case of modification: PLASTIC ATLAS | Appenzeller/Hecher/Sack (M) CC-BY-4.0).

creative commons

Cover copyright: Photo: ©Nora Bibel ©Montage: Annelie Saroglou using an image from Wetzkaz/Adobe Stock

# FOR ORDERS AND DOWNLOADS

Heinrich Böll Foundation, Schumannstraße 8, 10117 Berlin, www.boell.de/plasticatlas
Break Free From Plastic, www.breakfreefromplastic.org

# ពិភពផ្លាស្ទីក

ការពិត និងតួលេខស្តីពី ផ្លាស្ទីករាយពេញផែនដី

២០១៩

# អារម្ភកថា

ផ្លាស្ទីកមាននៅគ្រប់កន្លែង ហើយបើយើងគិតទៅ ជីវិតរបស់យើងពោរពេញទៅដោយផ្លាស្ទីក។ យើងប្រើប្រាស់ផ្លាស្ទីកស្រោបរក្សាឱសថ សម្លៀកបំពាក់ ប្រដាប់ក្មេងលេង និងសម្ភារៈថៃខ្លួន ក៏ដូចជានៅក្នុងសម្ភារៈនៃឧស្សាហកម្ម និងផលិតផលកសិកម្ម។ យើងក៏ដឹងពីហានិភ័យនៃកាកសំណល់ផ្លាស្ទីចនៅបរិស្ថានជុំវិញ តាមកន្លែងស្តុកទុកកាកសំណល់ និងនៅក្នុងទឹកសមុទ្រផងដែរ។

យើងឃើញកាន់តែច្បាស់ទៅៗថា ផ្លាស្ទីកបង្កហានិភ័យដល់សុខភាពយើង គិតចាប់តាំងពីដំណាក់កាលផលិត ការប្រើប្រាស់រហូតដល់ការបោះចោល។ ភាគល្អិតតូចនៃផ្លាស្ទិច និង ផលិតផលគីមីមានជាតិពុលដែលគេយកទៅផលិតផ្លាស្ទីក ចូលក្នុងខ្យល់ដង្ហើម ទឹកប្រើប្រាស់ ហើយនិងក្នុងដី។ វាធ្វើឱ្យខូចប្រព័ន្ធការពាររាងកាយពីជំងឺ ប្រព័ន្ធបន្តពូជ ថ្លើម តំរងនោម រហូតដល់ធ្វើឱ្យមានរោគមហារីក។

ទោះបីជាយើងដឹងថា ផ្លាស្ទីកធ្វើឲ្យខូចបរិស្ថាន និងសុខភាពក៏ដោយ ក៏ផលិតផលពីផ្លាស្ទីកនៅតែបន្តកើនឡើងជាលំដាប់។ និន្នាការនេះនឹងបន្តក្នុងពេលអនាគត ប្រសិនបើយើងមិនបង្អាក់ផែនការពង្រីកឧស្សាហកម្មទេនោះ ដោយសារតែការទាញយកឧស្ម័នសម្រាប់ផលិតវាមានតម្លៃថោក។

គ្រាន់តែនៅសហរដ្ឋអាមេរិក ក្រុមហ៊ុនឧស្សាហកម្មផ្លាស្ទីកមានគោលបំណងបង្កើនការផលិតផ្លាស្ទីក៣០ភាគរយនៅឆ្នាំបន្ទាប់ ។ ៩៩ភាគរយនៃផលិតផលផ្លាស្ទីក គេផលិតពីឥន្ធនៈហ្វូស៊ីល ដូចជាធ្យូងថ្ម ប្រេងកាត និងឧស្ម័ន។ ការធ្វើខូចដល់អាកាសធាតុ ដោយមានជាតិបំភាយឧស្ម័ន ពេលផលិតមានក្នុងធំធេងណាស់។

សម្រាប់ពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលមួយចំនួនចាប់ផ្តើមចាត់វិធានការ ដោយកំណត់ការប្រើប្រាស់ផ្លាស្ទីក ដូចជាហាមឃាត់លក់ដូរផលិតផលផ្លាស្ទីកដែលអាចប្រើបានតែមួយដង។ ប៉ុន្តែ បើយើងមិនកាត់បន្ថយផលិតផលផ្លាស្ទីកទេ ការចាត់វិធានការនេះមានឥទ្ធិពលតែបន្តិចបន្តួចប៉ុណ្ណោះ។ ការឃោសនាផ្សព្វផ្សាយ និងការធ្វើទីផ្សារយ៉ាងច្រើននៃឧស្សាហកម្មនេះធ្វើឲ្យយើងជឿថា យើងមិនអាចរស់នៅដោយមិនអាចគ្មានផ្លាស្ទីកបានទេ។ ដូច្នេះហើយពួកគេ (ឧស្សាហកម្ម) រុញទំនួលខុសត្រូវនៃ វិបត្តិផ្លាស្ទីក ពីក្រុមហ៊ុនផលិតផលទៅអតិថិជនអ្នកប្រើប្រាស់។

វិធីបំបែកកាកសំណល់ និង ការយកសំរាមទៅកែច្នៃឡើងវិញតែមួយមុខ មិនអាចដោះស្រាយបញ្ហាផ្លាស្ទីកបានទេ។ ដោយសារតែជំនួញកាកសំណល់ផ្លាស្ទិកមានការកើនឡើង បញ្ហាបណ្តាលមកផ្លាស្ទីកក៏កើនឡើងដូចគ្នា។ ប្រទេសជាច្រើនដូចជាប្រទេសអាល្លឺម៉ង់ជាដើម មិនបាននាំចេញតែកាកសំណល់ផ្លាស្ទីកភាគច្រើនទៅអាស៊ីអាគ្នេយ៍ទេ ពួកគេក៏នាំផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងសុខភាពទៅជាមួយដែរ។ ប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ មិនមានប្រព័ន្ធនៃការចោលសំរាមទេ បើមានក៏មិនគ្រប់គ្រាន់នៅឡើយ។ នៅទីបញ្ចប់ កាកសំណល់ផ្លាស្ទីកធ្លាក់ទៅក្នុងបរិស្ថាន ឬចូលក្នុងទឹក ឬសមុទ្រ។

ទោះយ៉ាងណាក៏ដោយ យើងនៅមានសុទិដ្ឋិនិយម ព្រោះថាផ្លាស្ទីកជាប្រធានបទសំខាន់មួយនៅលើរបៀបវារៈនយោបាយបច្ចុប្បន្ន ហើយមនុស្សទូទាំងពិភពលោកកំពុងបង្កើតចលនា "Break Free From Plastic" ជាមួយគ្នា។ គេបានចាប់ផ្តើមបង្កើនឡើងនូវនយោបាយមួយឈ្មោះថា "Zero-Waste" ឬ«យុទ្ធនាការមិនបង្កើតសំរាម» នៅតាមស្រុក និងទីក្រុង គ្រប់កន្លែងនៅទូទាំងពិភពលោក។ គោលដៅរបស់ពួកគេជាទូទៅនោះគឺ៖ ស្រាវជ្រាវរកមូលហេតុ ធ្វើការដោះស្រាយ និងរករបស់ផ្សេងៗទៀតមកជំនួស។

បើយើងមានចក្ខុវិស័យថា ផ្លាស្ទីកមិនត្រូវបំពុលបរិស្ថានពេញផែនដីយើងទេនោះ យើងត្រូវខិតខំប្រឹងប្រែងធ្វើឲ្យបានជោគជ័យ។ ប្រធានបទស្តីពីផ្លាស្ទីកនឹងតាមយើងជាប់ជានិច្ច ដែលធ្វើឲ្យយើងមិនអាចជៀសពីវាបាន។ ដូច្នេះ យើងត្រូវប្រុងប្រយ័ត្ន ហើយយកចិត្តទុកដាក់ខ្ពស់។ យើងកំពុងចាប់ផ្តើមយល់ដឹងអំពីទំហំនៃវិបត្តិនេះ។ បើយើងចង់កែប្រែវិបត្តិនេះឲ្យបានល្អវិញ យើងត្រូវមានចំណេះដឹងអំពីមូលហេតុភ្នាក់ងារផលិតផ្លាស្ទីក ហើយនិងបញ្ហាដែលបង្កដោយផ្លាស្ទីក។ ដូច្នេះហើយទើបយើងបោះពុម្ពសៀវភៅដែលមានចំណងជើងថា «ពិភពផ្លាស្ទីក» ឬ plastic atlas សម្រាប់លោកអ្នក។

យើងសង្ឃឹមថា លោកអ្នកអាចទទួលចំណេះវិជ្ជាថ្មីៗ នៅពេលលោកអ្នកសិក្សាសៀវភៅនេះ ហើយប្រឹងប្រែង និងលើកទឹកចិត្ត ព្រមទាំងកាន់តែសកម្មក្នុងការជួយដោះស្រាយបញ្ហានេះជាមួយគ្នា។

**បារបារា អ៊ុនមុសស៊ិក** ( Barbara Unmüßig )
មូលនិធិហោនរេចបូល (Heinrich-Boell-Foundation)

**ហ៊ូប៉ៀត វៃគា** ( Hubert Weiger )
សហព័ន្ធការពារធម្មជាតិនិងបរិស្ថាន នៃប្រទេសអាល្លឺម៉ង់ (Bund für Umwelt und Naturschutz Deutschland)

## វប្បធម៌បោះចោល

# ការទុកកាកសំណល់ឲ្យផែនដី

នៅសម័យឆ្នាំ១៩៥០ ប្រជាជនសាមញ្ញប្រើផ្លាស្ទីកថ្មៗ ដោយការយកចិត្តទុកដាក់ ហើយថែរក្សាវាយ៉ាងប្រុងប្រយ័ត្ន ប្រៀបដូចជាការប្រើដបកែវ ឬស្ងួត្រអញ្ចឹងដែរ។ ក្រោយមកក្រុមហ៊ុនផលិតសម្ភារៈប្រើប្រាស់មើលឃើញពីផលប្រយោជន៍ជាច្រើននៃផ្លាស្ទីកមាន។ ចាប់តាំងពីពេលនោះមក ជីវិតរស់នៅរបស់មនុស្សក៏ចាប់ផ្តើមបង្កើតសំណល់(ផ្លាស្ទីក)ច្រើនទៅៗដែរ។

ចាប់តាំងពីដំបូង រហូតដល់សតវត្សរ៍ទី២០ គេផលិតសម្ភារៈភាគច្រើនសម្រាប់ការប្រើប្រាស់រយៈពេលយូរ។ ហាងខ្នាតធំដែលលក់អីវ៉ាន់ដូចអាហារ និងភេសជ្ជៈ មានសម្ភារៈផ្ទុកអាហារ ឬភេសជ្ជៈដែលអតិថិជនអាចយក ឬចាក់បំពេញដបរបស់ពួកគេដោយខ្លួនឯង។ កញ្ចប់ ប្រអប់ និងដប គេអាចប្រើប្រាស់បន្តទៀត ឬ អាចយកទៅឲ្យហាងវិញក៏បាន។ ក្រោយសង្គ្រាមលោកលើកទី២ នៅពេលគេចាប់ផ្តើមដំណើរការផលិតកម្មទ្រង់ទ្រាយធំ ប្រជាពលរដ្ឋនៅតែប្រើប្រាស់ផលិតផលសំយោគយ៉ាងថ្នម ហើយពួកគេក៏ចេះថែរក្សាវាផងដែរ។

ចាប់ពីឆ្នាំ១៩៥០ អ្នកសេដ្ឋកិច្ច និងសាធារណៈទូទៅត្រូវការធនធានកាន់តែច្រើនឡើងៗ។ ឧស្សាហកម្ម(ផ្លាស្ទីក) រកឃើញលទ្ធភាពនៃការកាត់បន្ថយចំណាយ ហើយធ្វើឲ្យងាយស្រួលដល់ខ្សែសង្វាក់ផ្គត់ផ្គង់។ សម្ភារៈដែលប្រើប្រាស់រួចហើយ ត្រូវបានគេបោះចោលដូចជាសំណល់ ប្រអប់សម្រាប់ខ្ចប់ និងដប។ សង្គមដែលប្រើប្រាស់ហើយបោះចោល (throwaway society) បានកើនឡើងតាំងពីសម័យនោះមក។ នៅដើមឆ្នាំ១៩៦០ គេយកសំណល់ផលិតផលរាប់ពាន់លានទៅដាក់នៅពាសពេញកន្លែងស្តុកកាកសំណល់ និងនៅតាមឡដុតសំរាម នៅក្នុងប្រទេសជឿនលឿន។ កាលពីដំបូងការផ្លាស់ប្តូរទៅប្រើប្រអប់សម្រាប់ខ្ចប់ដែលប្រើរួចបោះចោលបានកើនឡើងយឺតៗ ប៉ុន្តែចាប់ពីទសវត្សរ៍ទី៧០មក ប្រអប់សម្រាប់ខ្ចប់ដែលប្រើហើយបោះចោលមានគ្រប់កន្លែងលើពិភពលោក។ នៅឆ្នាំ១៩៧៨ ក្រុមហ៊ុនកូកា កូឡាបាន

**ប្រភេទផ្លាស្ទីកមានខុសៗពីគ្នា ភាគច្រើនជាងគេគឺ ប្រអប់ខ្ចប់ដែលមិនអាចប្រើ និងអាយុកាលប្រើខ្លី។**

LIFE IS SHORT
Average useful life of various plastic items, by industrial sector, in years




© PLASTIC ATLAS 2019 / GEYER




ក្រុមហ៊ុនចំនួន៣២ បង្ហាញចំនួនផ្លាស្ទិកទាំងអស់ដែលគេបានផលិតក្នុងរយៈមួយឆ្នាំ នៅឆ្នាំ២០១៩។

យកដបផ្លាស្ទិកប្រភេទ PET មកជំនួសដបកែវដ៏ល្បីរបស់ខ្លួន។ វិធានការនេះបង្កើតបានជាយុគសម័យថ្មីមួយ(សម្រាប់ក្រុមហ៊ុនកូកាកូឡា)។

នៅពាក់កណ្តាលទសវត្សរ៍ទី៨០ ប្រទេសជឿនលឿនភាគច្រើនគិតថា បញ្ហាផលិតផលផ្លាស្ទិក ដែលប្រើបានតែមួយដង ហើយដែលកំពុងកើនឡើងច្រើនទៅៗនោះ ពួកគេអាចដោះស្រាយបានតាមរយៈការកែច្នៃឡើងវិញ។ ប៉ុន្តែនៅចុងទសវត្សរ៍ដដែល ដបដែលគេអាចប្រើសម្រាប់ ដាក់ទឹកក្រូច រឺទឹកដោះគោ ដែលអាចប្រើប្រាស់ឡើងវិញបាន មានសល់បន្តិចបន្តួចប៉ុណ្ណោះ។ បញ្ហានេះគឺដោយសារតែ គេបានយកដបផ្លាស្ទិក ដែលប្រើបានតែមួយដងមកជំនួស

**នៅប្រទេសលុចសំបួរ អៀរឡង់ និងអេស្តូនី ប្រជាជនម្នាក់ៗ ប្រើផ្លាស្ទិកច្រើនជាងគេ។ ប៉ុន្តែពីឆ្នាំ ២០១៥ ទៅ ២០១៦ ការប្រើប្រាស់មធ្យមនៅសហភាពអឺរ៉ុបចុះបន្ថយ។**



ដបប្រភេទនេះ។ ការប្រើសម្ភារៈដែលប្រើបានតែមួយដង ជួយឲ្យក្រុមហ៊ុនផលិតអាចដឹកជញ្ជូនផលិតផលទាំងនោះទៅដល់ទីផ្សារឆ្ងាយៗបាន ហើយងាយស្រួលលក់ដូរទៀត។ ស្របពេលជាមួយគ្នានេះ ប្រទេសកំពុងអភិវឌ្ឍន៍ចាប់ផ្តើមអនុវត្តតាមប្រទេសជឿនលឿន គឺធ្វើតាមរបៀបរបបដែលសង្គមនេះប្រើហើយបោះចោល ដោយសារតែពួកគេយល់ឃើញថា ការរស់នៅក្នុងជីវិតបែបនេះ ធ្វើឲ្យមានវឌ្ឍនធម៌ (រីកចម្រើន) និងមានភាពទំនើប។ នៅចុងសតវត្សរ៍ទី២០ ជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកាន់តែមមាញឹក(សកម្ម) ហើយចំនួនកម្មករក៏កាន់តែកើនឡើងច្រើនដែរ។ ទីក្រុងនានាកាន់តែរីកធំទៅៗ អ្នកធ្វើដំណើរទៅមកពីផ្ទះទៅកន្លែងធ្វើការក៏មានចំនួនកាន់តែច្រើនឡើងៗ។ គ្រួសារនីមួយៗមានពេលវេលាកាន់តែតិចសម្រាប់ការរៀបចំអាហារ ថៃសួនច្បារ និងថែរក្សាផ្ទះ ដោយសារគេចង់បានការកម្សាន្តច្រើនជាង។ គ្រួសារដែលមានមនុស្សតែម្នាក់ មានចំនួនកើនឡើងមួយជាពីរ តាំងពីឆ្នាំ១៩៥០។ គេយកអាហារដែលឆ្អិនស្រាប់ពីផ្សារ មកជំនួសម្ហូបដែលធ្វើស្រស់ៗដោយខ្លួនឯង។

វាជាបែបបទនៃការរស់នៅមួយដែលប្រើសម្ភារៈប្រើបានតែម្តងផលិតពីផ្លាស្ទិក ព្រោះវាសម្រួលដល់ជីវិតរបស់យើង ដូចជាបំពង់បឺត ថង់ ឈុតគ្រឿងតុទូ ដប និងកែវភេសជ្ជៈ។ សម្ភារៈទាំងអស់នេះគេអាចរកបានយ៉ាងរហ័ស ងាយស្រួលប្រើ រួចហើយអាចបោះចោលតែម្តង។ សម្ភារៈប្រើបានភ្លាមៗបានក្លាយជារបៀបរស់នៅ ក្នុងសម័យសេដ្ឋកិច្ចមូលធននិយម។ នេះគឺជាហេតុផល និងផលវិបាកកើតចេញពីការរីកចម្រើននៃជីវិតសម័យទំនើបដ៏ឆាប់រហ័ស។

គំនិតបែបនេះ យើងអាចមើលឃើញតាមទូរទស្សន៍ ខ្សែភាពយន្តហូលីវូដ និងតាមរយៈព្រឹត្តិការណ៍កីឡានានា។ រឿងកុនល្បីល្បាញជួយផ្សព្វផ្សាយផលិតផលប្រើហើយបោះចោល និងណែនាំវប្បធម៌ប្រើហើយចោលរាលទៅទូទាំងពិភពលោក។ មនុស្សនៅក្នុងតំបន់ក្រីក្រអនុវត្តតាមច្រើនដោយសារពួកគេគិតថា ធ្វើរបៀបនេះវាមានកិត្យានុភាពខ្ពស់។ សហគ្រាស និងក្រុមហ៊ុនធំៗជួយឲ្យនិន្នាការបែបនេះ កើនឡើងកាន់តែខ្លាំង។

នៅក្នុងព្រឹត្តិការណ៍ធំៗ មានកាកសំណល់មិនតិចទេ ដែលឡានត្រូវដឹកទៅដុត ឬយកចាក់ទុកកន្លែងចាក់សំរាម។ ប៉ុន្តែនៅកន្លែងខ្លះ គេចាប់ផ្តើមអនុញ្ញាតឲ្យប្រើតែកែវដាក់ប្រាក់កម្ពល់ប៉ុណ្ណោះ និងប្រើចានដែលអាចរលាយឆាប់រហ័ស។ លើសពីនេះទៀត អ្នកផ្គត់ផ្គង់អាហារ និង ភេសជ្ជៈដែលយកទៅបរិភោគកន្លែងផ្សេង (To-Go) បញ្ចុះតម្លៃសម្រាប់អតិថិជនណាដែលយករបស់មកតាមខ្លួនដើម្បីដាក់វត្ថុដែលខ្លួន។ ទោះយ៉ាងណាក៏ដោយ ផ្នត់គំនិតប្រើហើយបោះចោលនៅតែកើតមានឡើងច្រើនដដែល ពីព្រោះវាធ្វើឲ្យជីវិតយើងមានភាពងាយស្រួល។ តម្លៃនៃសម្ភារៈ ឬផលិតផលនានា មិនទាន់បានបញ្ចូលតម្លៃនៃសំណល់នៅឡើយ។

ប្រទេសនីមួយៗ មានយន្តការខុសៗគ្នា។ នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ក្រុមហ៊ុនធំៗដូចក្រុមហ៊ុន Procter & Gamble ផលិតសម្ភារៈ ដាក់ចូលក្នុងប្រអប់ខ្ចប់តូចៗ។ ពួកគេពន្យល់ថា អតិថិជនមានប្រាក់ចំណូលទាប ដូច្នេះពួកគេអាចទិញផលិតផលនេះបាន បើសិនក្រុមហ៊ុនធ្វើរបៀបនេះ។ ប៉ុន្តែលទ្ធផលរបៀបនេះធ្វើឲ្យមានសំរាមកើនឡើងកាន់តែខ្លាំង។

ការគិតដូច្នេះខុសធ្ងន់ណាស់ ដោយសារវាធ្វើឲ្យមានតម្រូវការកញ្ចប់(ផ្លាស្ទិក)ច្រើនហួសហេតុ ហើយម្យ៉ាងវិញទៀត វាធ្វើឲ្យមនុស្សទិញរបស់របរកាន់តែច្រើន បើទោះបីជារបស់ទាំងនោះមិនចាំបាច់សម្រាប់ពួកគេក៏ដោយ។ វាជារឿងសំខាន់មួយដែលយើងត្រូវចាំថា មហន្តរាយនៃផ្លាស្ទិកកើតឡើងនៅកន្លែងដែលមានការខ្វះខាតទឹក។ មនុស្សនៅតំបន់នេះត្រូវទិញទឹកដែលច្រកដបផ្លាស្ទិកមកប្រើប្រាស់។ បើសិនការចោលសំរាមរបស់ពួកគេមិនត្រូវបានធ្វើឡើងដោយត្រឹមត្រូវទេនោះ ពួកគេនៅទីនោះនឹងលិចលង់ខ្លួនឯងទៅនឹងគំនរសំរាម។

អ្នកផលិតផ្លាស្ទិកមិនជួយរកដោះស្រាយលើ បញ្ហាសំរាមទេ ឧទាហរណ៍ពួកគេមិនជួយរកកន្លែងចោលសំរាម ឬក៏ការកែច្នៃវាឡើងវិញឡើយ។ នៅតាមទីក្រុងនៃប្រទេសកំពុងអភិវឌ្ឍន៍ អាហារកញ្ចប់ ឬផលិតផលដែលងាយស្រួលប្រើ (Convenience Item) បានក្លាយទៅជាបញ្ហាដ៏ធំដែលមិនទាន់រកដំណោះស្រាយឃើញ។ ប្រជាជនមិនទាន់គិតឃើញពីហេតុផលដែលគេត្រូវប្រមូលសំរាម រួចហើយយកវាទៅបោះចោលនៅកន្លែងសមរម្យនោះទេ។

# ការប្រើប្រាស់
# ពរជ័យ ឬបណ្ដាសារ

ជារៀងរាល់ថ្ងៃ យើងមិនអាចរស់នៅគ្មានផ្លាស្ទីកបានទេ ដោយសារវាមាននៅក្នុងសម្ភារៈនានាជាច្រើន ដូចជាថង់ ស្មាតហ្វូន និងនាឡិកា។ សម្ភារៈផ្លាស្ទីកជិត ៥០ភាគរយ អាចប្រើបានតែមួយខែ បន្ទាប់មកវាក្លាយទៅជាសំរាម។ ការកែច្នៃឡើងវិញអាចធ្វើបានតែក្នុងបរិមាណតិចតួចប៉ុណ្ណោះ។

ចាប់តាំងពីឆ្នាំ ១៩៥០ រហូតដល់ឆ្នាំ ២០១៥ គេបានផលិតផ្លាស្ទីកទម្ងន់សរុប ៨.៣ ពាន់លានតោន។ បើយើងប្រៀបធៀបទៅ មនុស្សម្នាក់ៗដែលរស់នៅបច្ចុប្បន្នមានផ្លាស្ទីកមួយតោន។ ការពិតតំបន់សំខាន់ដែលផលិត និងប្រើប្រាស់ផ្លាស្ទីកច្រើនជាងគេមានតែពីរឬបីកន្លែងប៉ុណ្ណោះ។ តំបន់ទាំងនេះគឺប្រទេសចិន អាមេរិកខាងជើង និងអឺរ៉ុបខាងលិច។




គេយកផ្លាស្ទីកទៅប្រើនៅគ្រប់ផ្នែកក្នុងឧស្សាហកម្ម និងជីវិតប្រចាំថ្ងៃ ដោយសារវាទុកបានយូរអង្វែង មានភាពស្រាល និងយឺតល្អ។ ទោះបីជាពីដំបូងគេមានបំណងយកផ្លាស្ទីកទៅប្រើជាសម្ភារៈមានគុណភាពខ្ពស់ក៏ដោយ តែទីបញ្ចប់សព្វថ្ងៃនេះ គេបានត្រឹមតែយកវាទៅខ្ចប់អីវ៉ាន់សម្រាប់ប្រើប្រចាំថ្ងៃ ឬប្រើរួចបោះចោលប៉ុណ្ណោះ។ ផលិតផលសព្វថ្ងៃប្រើបានតែមួយដង ឬប្រើបានក្នុងរយៈពេលខ្លីហើយក៏ត្រូវបានបោះចោលជាសំរាម។ គុណភាពសារធាតុផ្លាស្ទីកមានទាំងល្អទាំងអាក្រក់។ ជាតិផ្លាស្ទីកធន់បានយូរមិនឆាប់ខូច។ ដូច្នេះហើយ វាមិនងាយរលាយបាត់ទេ។

គេចូលចិត្តយកផ្លាស្ទីកទៅខ្ចប់អាហារ និងសម្ភារៈនានាដោយមានហេតុផលជាច្រើន។ លក្ខណៈរបស់វានៅដដែលពេលសីតុណ្ហភាពផ្លាស់ប្តូរពីក្តៅទៅត្រជាក់ ឬពីត្រជាក់ទៅក្តៅ។ ហើយម្យ៉ាងវិញទៀតវាអាចមានភាពបត់បែន ឬភាពរឹងមិនអាចបត់បែន។ គ្រឿងផ្លាស្ទីកប្រភេទប៉ូលីអេធីឡែន (Polyethylen) មានដង់ស៊ីតេទាប (LDPE) មានភាពយឺត ដែលអាចពត់បត់បាន និងមានភាពថ្លា។ ហេតុដូច្នេះហើយ គេយកវាទៅធ្វើសន្លឹកផ្លាស្ទីកសម្រាប់ជាស្រោមដើម្បីរុំរបស់ផ្សេងៗ។

គ្រឿងផ្លាស្ទីកប្រភេទ PET អាចទប់ខ្យល់ និងការពារ

**វិបត្តិនៅពិភពលោកដែលពោរពេញទៅដោយផ្លាស្ទីកប្រើប្រាស់បានតែមួយដង។ កន្លែងផលិតផ្លាស្ទីកមាននៅតែកន្លែងមួយចំនួនតិចតែប៉ុណ្ណោះ។**




## ក្នុងមួយឆ្នាំពិភពលោកផលិតផ្លាស្ទីកចំនួន ៤០០លានតោន។ មួយភាគបីគឺជាប្រអប់ផ្លាស្ទីក។

ការជ្រាបទឹកបាន។ គេយកផ្លាស្ទីកប្រភេទនេះទៅផលិតជាដបផ្លាស្ទីក PET។ ជាតិផ្លាស្ទីកប៉ូលីប្រូភីលេន (Polypropylen) ធន់នឹង កំដៅខ្ពស់ និងជាតិគីមីនានា។ គេផលិត

**ចាប់តាំងពីឆ្នាំ ២០០០ ផ្លាស្ទីកកាន់តែផលិតច្រើនជាងកាលពី ៥០ ឆ្នាំមុន។ ការបង្ហាញផលិតផលផ្លាស្ទីកបន្តផ្ទុះឡើង។**



ប្រអប់(ដប)ពីជាតិផ្លាស្ទិកប្រភេទនេះសម្រាប់ដាក់ទឹកក្តៅ។ ជ័រផ្លាស្ទិកប្រភេទប៉ូលិស្ទីរោល (Polystyrol) មានភាពរឹង និងសភាពផ្សេងទៀត ដែលគេយកទៅធ្វើប្រអប់ការពារ ការចម្លងមេរោគ និងប្រអប់ដាក់អាហារ។ ម្យ៉ាងទៀតគេយកគ្រឿងភីវីស៊ី (PVC) ទៅផលិតជាកញ្ចប់ដោយសារវារាំងអុកស៊ីសែននិងជាតិរាវមិនឲ្យភាយចេញបាន។

វិស័យសំណង់ក៏ប្រើប្រាស់ផ្លាស្ទិកច្រើនដែរ សម្រាប់ធ្វើកម្រាល ទ្វារ បង្អួច និងបំពង់លូ។ សម្ភារៈផ្លាស្ទិកទាំងនេះអាចទុកយូរបាន ដោយវាមានភាពយឺត ជួយការពារកុំឲ្យមានច្រេះស៊ី ឬដុះផ្សិតល្វយ។ បើប្រៀបធៀបទៅនឹងគ្រឿងផ្សេងៗទៀត ផ្លាស្ទិកងាយស្រួលប្រើ ហើយងាយស្រួលប្តូរបានយ៉ាងលឿន។ ម្យ៉ាងទៀត វាជួយការពារកំដៅភាពត្រជាក់ និងជួយបន្ថយការប្រើប្រាស់ភ្លើងអគ្គិសនីច្រើន។

គ្រឿងផ្លាស្ទិកដែលគេយកទៅប្រើនៅក្នុងវិស័យសំណង់គឺផ្លាស្ទិកប្រភេទភីវីស៊ី (PVC) ដោយសារ PVC មានគុណភាពល្អ ដូចជារឹងមាំ ជាប់បានយូរ និងស្រាល។ លូបំពង់ផលិតពីជាតិផ្លាស្ទិកប្រភេទ HDPE (High-Density-Polyethylene) មានកំហាប់ខ្ពស់ រឹងមាំខ្លាំង និងមិនច្រេះស៊ី។ ម្យ៉ាងទៀតផ្លាស្ទិកប្រភេទនេះមានភាពយឺតទន់ដូច្នេះហើយគេអាចពត់បត់វាបាន និងអាចទាញវាចេញពីលូផ្សេងៗបានយ៉ាងងាយស្រួល។

ចុងបំផុត សូម្បីយន្តហោះ ឡាន កប៉ាល់ ឬរថភ្លើង មិនអាចផលិតដោយគ្មានផ្លាស្ទិកបានទេ ដោយសារផ្លាស្ទិកមានភាពរឹងមាំ ស្រាល យឺតល្អ និងអាចកែច្នៃឡើងវិញបាន។ ក្រៅពីនេះ គេមិនចាំបាច់ថែទាំវាប៉ុន្មានទេ ហើយវាអាចទប់ទល់នឹងរំញ័រខ្លាំងបានទៀតផង។ ជារៀងរាល់ថ្ងៃយើងនឹងគ្មានមានឡានជិះទេ បើយើងគ្មានគ្រឿងផ្លាស្ទិក។ ភាគច្រើនគេយកវាទៅប្រើប្រាស់នៅខាងក្នុងឡាន ដូចជាធ្វើជាទ្រនាប់កៅអី គ្រឿងការពារការប៉ះទង្គិច សមាសធាតុអេឡិចត្រូនិចឡាន និងផ្ទៃតាប្លូ។ ដោយសារការផលិតនាវាដែលមានទម្ងន់ស្រាលនិងប្រើប្រេងឥន្ធនៈតិច មានការកើនឡើង គេនឹងប្រើគ្រឿងសរសៃផ្លាស្ទិកសម្រាប់ ពង្រឹងគុណភាពវា (Fiber-Reinforced Plastic) ដូចជា ជាតិកញ្ចក់សរសៃ (Glass Fiber) និងជាតិសរសៃកាបូន (Carbon Fiber)។ ផ្លាស្ទិកប្រភេទទាំងនេះមិនមានច្រេះ ហើយទឹកសមុទ្រក៏មិនស៊ីបណ្តាលឲ្យនាវាទាំងនោះខូចដែរ។ ហេតុដូច្នេះហើយគេមិនចាំបាច់ថែទាំវាញឹកញាប់ពេកទេ ហើយចំណាយសម្រាប់ប្រតិបត្តិការក៏ថយចុះដែរ។

នៅលើតួយន្តហោះ និងយានអវកាស គ្រឿងនីមួយៗត្រូវមានភាពធន់ទៅនឹងអាកាសធាតុក្តៅខ្លាំង និងត្រជាក់ខ្លាំង មានភាពស៊ាំការពារច្រេស ឧស្ម័ន និងសារជាតិគីមី។ ផ្លាស្ទិកប្រភេទភីវីស៊ី (PVC) អេគ្រីលិក (Acrylic) និងផូលីយ៉ាមីត (Polyamide) មិនអាចខ្វះបានទេនៅក្នុងយានអវកាស និងយន្តហោះ ឧទាហរណ៍ ដូចជាទ្វារ បន្ទប់ទឹក ឬជញ្ជាំង។ ចាប់តាំងពីឆ្នាំ ១៩៧០ រហូតមកដល់បច្ចុប្បន្ននេះ ការប្រើប្រាស់ផ្លាស្ទិកនៅលើយន្តហោះកើនឡើងពី៤ភាគរយ ដល់ ៥០ ភាគរយ។

ដោយសារតម្រូវការផ្លាស្ទិកកើនឡើងខ្លាំង ការដោះស្រាយបញ្ហាកាកសំណល់ក៏ត្រូវតែមានច្រើនដែរ។ តាមការប៉ាន់ស្មាន សព្វថ្ងៃនេះ ៤០ ភាគរយនៃផលិតផលផ្លាស្ទិកបានក្លាយទៅជាសំរាមក្នុងពេលរយៈមួយខែ។ សំរាមផ្លាស្ទិកនេះកើនឡើងច្រើនឡើងដែលធ្វើឲ្យមានបញ្ហាធំ ប៉ះពាល់បរិស្ថាន។ ការកែច្នៃដើម្បីប្រើប្រាស់ឡើងវិញគ្រាន់តែជាជម្រើសទីពីរប៉ុណ្ណោះ។ គេព្យាករណ៍ថា ចាប់ពីឆ្នាំ ២០២៥ តទៅ យើងនឹងផលិតផ្លាស្ទិកជាង៦០០លានតោន ក្នុងរយៈពេលមួយឆ្នាំ។ ប្រព័ន្ធកែច្នៃបច្ចុប្បន្នមិនអាចដោះស្រាយបញ្ហាសំណល់នោះបានទេ។ ចាប់តាំងពីឆ្នាំ ១៩៥០ មកដល់បច្ចុប្បន្ន គេបានកែច្នៃផ្លាស្ទិកត្រឹមតែ៩ភាគរយប៉ុណ្ណោះចេញពីផ្លាស្ទិក៨ពាន់លានតោន។ ជម្រើសល្អបំផុតដើម្បីដោះស្រាយបញ្ហានេះ គឺយើងត្រូវឈប់ផលិតផ្លាស្ទិកច្រើន។ ប៉ុន្តែនេះជាជម្រើសដែលពិបាកនឹងធ្វើ។

សុខភាព

# គីមីចំណីអាហារ

## ផលប៉ះពាល់នៃផលិតផលផ្លាស្ទិចដែលហៀរចេញលើបរិស្ថានមិនអាចត្រូវបានគេព្រងើយកន្តើយទៀតនោះឡើយ។ ផលប៉ះពាល់របស់វាចំពោះសុខភាពមនុស្សមិនសូវត្រូវបានគេដឹងទេ គឺរាប់ចាប់ពីការទាញយកវត្ថុធាតុដើម រហូតដល់ការបោះចោលកាកសំណល់។

វត្ថុផ្លាស្ទីកជាច្រើនចាប់ផ្តើមជីវិតដូចជាប្រេងឥន្ធនៈ ឬឧស្ម័នធម្មជាតិ។ នៅពេលប្រេងឬឧស្ម័នកំពុងត្រូវបានបូមទាញយកចេញពីក្នុងក្រោមដី ជាពិសេសដោយប្រើបច្ចេកទេសគ្រោះថ្នាក់មួយចំនួន នោះសារធាតុពុលក៏ត្រូវបានបញ្ចេញទៅក្នុងខ្យល់ និងទឹកផងដែរ។ សារធាតុជាង ១៧០ មុខ ដែលត្រូវបានប្រើក្នុងការទាញយក ត្រូវបានគេដឹងថាអាចបណ្តាលអោយមានជំងឺមហារីក សុខភាពបង្កកំណើត និងបំផ្លាញដល់ប្រព័ន្ធការពារភាពស៊ាំ។ ជាពិសេស ប្រជាជនដែលរស់នៅក្បែរអណ្តូងដែលទាញយកប្រេង ឬក៏ឧស្ម័ន រងផលប៉ះពាល់ពីសារធាតុទាំងនេះ ព្រមទាំងការបំពុលពីរថយន្តជាច្រើនដែលត្រូវបានប្រើសម្រាប់ដឹកជញ្ជូនប្រេងម៉ាស៊ូតនៅក្នុងតំបន់នេះ។ ដើម្បីរៀបចំទីតាំងចម្រាញ់ប្រេងឬឧស្ម័នមួយ គេត្រូវការរថយន្តរហូតដល់ទៅ ៦,០០០ គ្រឿងយកមកដឹកសម្ភារៈ ទឹក និងសារធាតុគីមីផ្សេងៗ។ ការស្រាវជ្រាវមួយនៅសហរដ្ឋអាមេរិកបានបង្ហាញថា ចំពោះស្ត្រីមានផ្ទៃពោះដែលរស់នៅក្បែរទីតាំងចម្រាញ់ប្រេង ឬឧស្ម័នមានហានិភ័យខ្ពស់នៃគ្រោះថ្នាក់ពេលសម្រាលកូន និងការសម្រាលកូនមិនគ្រប់ខែ។

**សារធាតុគីមីជាច្រើននៅក្នុងប្លាស្ទិចមានឥទ្ធិពលលើសុខភាពមនុស្ស។ ផលវិបាកអាចមានទាំងធ្ងន់ធ្ងរព្រមទាំងរយៈពេលវែង។**

ការបំលែងប្រេងទៅជាផ្លាស្ទិចមានន័យថា ជាការចម្រាញ់ ហើយបំបែកវាទៅជាម៉ូលេគុលតូចជាងមុន។ នៅពេលនោះ ម៉ូលេគុលត្រូវបានច្របាច់បញ្ចូលគ្នានៅក្នុងប៉ូលីមែរដែលជាខ្សែសង្វាក់មានរយៈពេលយូរជាងមុនដោយ មានការលាយជាមួយសារធាតុគីមី ដុតកំដៅ និងដាក់សម្ពាធជាដើម។ សារធាតុផ្សេងៗទៀតត្រូវបានដាក់បន្ថែមដើម្បីទទួលបាននូវសម្ភារៈដែលមានលក្ខណៈដូចគេចង់បាន។ ជាឧទាហរណ៍៖ ប្លាស្ទិចបំលែងPVC រឹងមាំទៅជាទន់អាចបត់បែនបានហើយត្រូវប្រើដើម្បីផលិតអាងហែលទឹក។ សមាសធាតុហ្លួយអូរីនត្រូវបានប្រើដើម្បីធ្វើអាវពាក់ពីក្រៅអាចការពារនឹងអាកាសធាតុខាងក្រៅបាន។ សារធាតុប្រូមដើរតួសំខាន់ក្នុងការពន្យាពេលនៃចំហេះចំពោះសម្ភារៈប្រើអគ្គិសនីនិងគ្រឿងសង្ហារឹម ផ្សេងៗ។ ជាមធ្យមផលិតផលផ្លាស្ទីកមានផ្ទុកប្រហែល ៧ ភាគរយនៃ






> ទោះបីជាអ្នកព្យាយាមមិនប៉ះពាល់ ឬប្រើប្រាស់ផ្លាស្ទីកក៏ដោយ អ្នកនៅតែប្រឈមនឹងវា។ រាងកាយមនុស្សមិនមានអ្វីការពារនោះទេ។

សារធាតុបន្ថែមទាំងនេះ។ សម្រាប់បាល់ធ្វើពី PVC មានផ្ទុកផ្លាស្ទិចរហូតដល់ ៧០ ភាគរយនៃទំងន់សរុបរបស់វា។

សារធាតុបន្ថែមទាំងនេះភាគច្រើនបង្កគ្រោះថ្នាក់ដល់សុខភាព។ ពួកវាសាយភាយបន្តិចម្តងៗ និងជ្រាបចូលទៅក្នុងចំណីអាហារ ខ្យល់អាកាស និងធូលីក្នុងផ្ទះជាដើម។ ការសិក្សារបស់សហរដ្ឋអាមេរិកបានរកឃើញថាកុមារដែលតែងតែបរិភោគអាហារថ្ងៃត្រង់នៅសាលាងាយប្រឈមនឹង phthalates ដែលជាសមាសធាតុប្លាស្ទិកត្រូវបានប្រើនៅក្នុងប្រអប់ដាក់ចំណីអាហារ ច្រើនជាងកុមារដែលមិនដែលបរិភោគអាហារទាំងនោះ។

ការសិក្សាស្រាវជ្រាវអំពីឈាមរបស់ជនជាតិអាមេរិកដែលមានគភ៌បានរកឃើញនូវសារធាតុគីមីឧស្សាហកម្មចំនួន ៥៦ ផ្សេងៗគ្នាជាមធ្យម ដែលភាគច្រើនមានប្រភពចេញពីផលិតផលប្លាស្ទិច ឬសមាសធាតុដែលត្រូវបានប្រើដើម្បីប្លាស្ទិក។ ប្រហែលនៅតែសមាសធាតុផ្សេងទៀត គ្រាន់តែមិនត្រូវបានគេសិក្សាប៉ុណ្ណោះ។ ការស្រាវជ្រាវនៅប្រទេសអាឡឺម៉ង់បានរកឃើញថា ជាពិសេសកូនក្មេងដែលប៉ះពាល់ជាមួយប្លាស្ទិចអាចមានគ្រោះថ្នាក់ដល់សុខភាពបន្តពូជរបស់ពួកគេ។ ដោយសារតែទំងន់រាងកាយរបស់កុមារ ពួកគេត្រូវខ្យល់ដកដង្ហើមច្រើននិងមានអត្រាមេតាប៉ូលីសខ្ពស់ជាងមនុស្សធំ។ ពួកគេនៅកៀកនឹងដី ហើយជារឿយៗលេងនៅលើដីតែម្តងដែលងាយប្រឈមនឹងការបំពុលកាន់តែខ្លាំង។

ជាពិសេសគឺមានការព្រួយបារម្ភចំពោះសារធាតុដែលបង្កអន្តរាយប្រព័ន្ធអង់ដូគ្រីន ដោយមានទាំងសមាសធាតុជាច្រើនសម្រាប់ផលិតប្លាស្ទិច។ សមាសធាតុទាំងនេះធ្វើត្រាប់តាមអរម៉ូនដែលកើតឡើងដោយធម្មជាតិនិង ធ្វើការរំខានដល់តុល្យភាពនៃប្រព័ន្ធក្រពេញអង់ដូគ្រីននៅក្នុងរាង្គកាយ។ ជំងឺ និងភាពមិនប្រក្រតីជាច្រើនសុទ្ធតែពាក់ព័ន្ធនឹងសារធាតុសកម្មនៃអរម៉ូន។ ទាំងនេះរួមមាន៖ ជំងឺមហារីកសុដន់ ភាពគ្មានកូន ការពេញវ័យមុនអាយុ ធាត់អាឡែរហ្ស៊ី និងជំងឺទឹកនោមផ្អែមជាដើម។

គ្មាននរណាម្នាក់ដឹងលម្អិតអំពីសារធាតុគីមីនៅក្នុងទំនិញដែលយើងប្រើប្រាស់នោះទេ។ អតិថិជនមិនអាច កំណត់អត្តសញ្ញាណសារធាតុគីមីដែលអាចបង្កគ្រោះថ្នាក់នៅក្នុងផលិតផលនោះទេ។ អ្នកលក់រាយភាគច្រើនមិនដឹងថាមានអ្វីខ្លះនៅក្នុងផលិតផលដែលពួកគេលក់នោះឡើយ ជាធម្មតាព័ត៌មាននោះបានបាត់បង់តាមរយៈសង្វាក់ផលិតកម្មដែលចំណាយពេលយូរ និងរញេរញៃ រឺក៏ត្រូវ បានលាក់បាំងដោយចេតនាពីក្រុមហ៊ុនផលិត ដោយសំអាងថាជាព័ត៌មាន "ពាណិជ្ជកម្មសម្ងាត់"។ វាពិតជាចាំបាច់ណាស់ដែលត្រូវដាក់បង្ហាញសាធារណៈនូវព័ត៌ស្តីពីការប្រើប្រាស់សារធាតុគីមីនៅក្នុងប្លាស្ទីក និងសមាសធាតុគីមីពិតប្រាកដដែលមាននៅក្នុងផលិតផលពីប្លាស្ទិច។

សេដ្ឋកិច្ចចក្រា(Circular Economy)នឹងទទួលបានអត្ថប្រយោជន៍ពីតម្លាភាព។ បច្ចុប្បន្ននេះ ឧស្សាហកម្មប្រើវត្ថុធាតុដើមដែលមិនសមស្របសម្រាប់សុខភាពមនុស្ស និងបរិស្ថានដោយបំលែងទៅជារបស់របរផ្សេងៗដូចជា៖ ប្រដាប់ប្រដាក្មេងលេង និងឧបករណ៍ដាក់ចំណីអាហារដែលកាន់តែកខ្វក់ខ្លាំង។ ការស្រាវជ្រាវដោយអង្គភាពបរិស្ថានមកពី ១៩ ប្រទេសនៅអ៊ឺរ៉ុបបានរកឃើញថា ផលិតផលមួយក្នុងចំណោមផលិតផលបួនដែលផលិតពីប្លាស្ទិចកែច្នៃមានផ្ទុកនូវសមាសធាតុការពារចំហេះ ដែលបង្កគ្រោះថ្នាក់ខ្លាំងដល់សុខភាព។ ជាតិពុលនៅក្នុងរបស់របរកែឆ្នៃភាគច្រើនចេញពីកាកសំណល់អគ្គិសនីដែលយកកែច្នៃឡើងវិញ។ ការកែច្នៃឡើងវិញពិតជាមានគ្រោះថ្នាក់ជាពិសេសចំពោះអ្នកដែលរើសវត្ថុធាតុដើមដែលមានជាតិកខ្វក់ទាំងនោះ។ វដ្តនៃជាតិពុលនេះអាចត្រូវបានបញ្ឈប់ ប្រសិនបើអ្នកផលិតទទួលខុសត្រូវចំពោះការចោលកាកសំណល់ទាំងនោះ។ គោលការណ៍ទូទៅគឺថាអ្វីដែលដែលដាក់ចូលនៅចុងម្ខាងនឹងចេញមកវិញនៅចុងម្ខាងទៀត។ ការប្រើប្រាស់វត្ថុធាតុដើមដែលមានជាតិពុលនៅក្នុងប្លាស្ទីកគួរតែត្រូវបានជៀសវាងទាំងអស់គ្នា។

តាមទស្សនៈពិភពលោក ការកែច្នៃប្លាស្ទិកដើរតួនាទីតិចតួចបំផុត។ នាពេលបច្ចុប្បន្ននេះមិនមានអ្វីដូចជាការកែច្នៃប្លាស្ទិចទេ មានតែការកែច្នៃឡើងវិញឬការជិះកង់ចុះក្រោម។ រាល់ពេលដែលប្លាស្ទីកមួយដុំត្រូវបានកែច្នៃឡើងវិញ គុណភាពរបស់វាគឺថយចុះ។ ប្លាស្ទីកអាចត្រូវបានកែច្នៃបានតែប៉ុន្មានដងប៉ុណ្ណោះ មុនពេលដែលវាត្រូវបានបោះចោលនៅក្នុងកន្លែងចាក់សំរាម

ឬឡដុត។ ដូច្នេះអ្វីដែលយើងហៅថាការកែច្នៃផ្លាស្ទីកពិតនោះ គ្រាន់តែការពន្យាពេលនៃការបោះចោលប៉ុណ្ណោះ។

នៅក្នុងការព្យាយាមគ្រប់គ្រងបរិមាណសំណល់ផ្លាស្ទីកដែលកំពុងកើនឡើងជាលំដាប់ សាលាក្រុងនិងរដ្ឋាភិបាលកំពុងងាកទៅរកការដុតបំផ្លាញវិញ។ ប៉ុន្តែនេះគ្រាន់តែផ្លាស់ប្តូរបញ្ហានៅកន្លែងផ្សេងទៀត។ សារធាតុដែលបំភាយចេញពីឡដុតរួមមាន៖ ឌីអុកស៊ីត និងលោហធាតុដូចជា បារត សំណ និងកាឌីមីញ៉ូម។ កម្មករ និងសហគមន៍ដែលនៅក្បែរនោះរងផលប៉ះពាល់ជាពិសេស ហើយជាតិពុលក៏អាចហើយបានឆ្ងាយ ព្រមទាំងស្ថិតនៅក្នុងដីនិងទឹកផងដែរ។ ម្យ៉ាងទៀត ការដុតផ្លាស្ទិចក៏បង្កើតបានជាផលិតផលដែលមានជាតិពុលខ្ពស់ ជាផេះ ឬភក់ ហើយនេះជាបញ្ហាកាកសំណល់ថ្មីមួយទៀត។ កាកសំណល់ទាំងនេះត្រូវបានដាក់ចូលក្នុងរណ្តៅដី រូងភ្នំ ដីស្រែចំការ និងទីវាលសើមដែលបង្កការគំរាមកំហែងយូរអង្វែងដល់បរិស្ថាននិងសុខភាព។ ការដុតជាលក្ខណៈចំហរបង្កជាបញ្ហាជាងនេះទៅទៀត ទង្វើបែបនេះត្រូវបានធ្វើជាញឹកញាប់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍និងទីជនបទដែលមិនមានលទ្ធភាពគ្រប់គ្រងសំណល់។ ដើម្បីដោះស្រាយផលប៉ះពាល់សុខភាពពីផលិតផ្លាស្ទីក ទាមទារឲ្យមានចំណាត់ការចំពោះការប្រើប្រាស់និងការបោះចោលកាកសំណល់ក៏ដូចជាសង្វាក់ផលិតកម្មទាំងមូល។ រឿងមួយដែលត្រូវធ្វើឲ្យច្បាស់លាស់គឺថា៖ **តម្លាភាពគឺជាគន្លឹះនៃភាពជោគជ័យ។**

## យេនឌ័រ

# ការប្រឈមមុខហួសពីកម្រិតដែលអាចទទួលបាន

**ស្ត្រីរងផលប៉ះពាល់ដោយផ្លាស្ទីកខ្លាំងជាងបុរស។ មូលហេតុជីវសាស្ត្រគឺជាផ្នែកមួយនៃបញ្ហានេះ រាងកាយរបស់ពួកគេមានប្រតិកម្មចំពោះជាតិពុលតាមរូបភាពផ្សេងៗគ្នា ហើយផលិតផលអនាម័យដែលស្ត្រីប្រើប្រាស់ជាញឹកញាប់ងាយនឹងឆ្លងមេរោគ។ ប៉ុន្តែទោះជាយ៉ាងណា ជម្រើសជំនួសពិតជាមាន។**

សារធាតុពុលដែលមាននៅក្នុងផ្លាស្ទីកមានផលប៉ះពាល់លើបុរស និងស្ត្រីខុសៗគ្នា ទាំងនៅកន្លែងធ្វើការ និងនៅក្នុងជីវិតប្រចាំថ្ងៃ។ នេះគឺដោយសារតែមូលហេតុជីវសាស្ត្រ ភាពខុសគ្នានៃទំហំរាងកាយ និងសមាមាត្រនៃជាលិកាខ្លាញ់ ហើយក៏ដោយសារតែតួនាទីយេនឌ័រដែលស្ត្រីយល់ថាខ្លួនឯងត្រូវតែបំពេញដែរ។ រាងកាយរបស់ស្ត្រីផ្ទុកខ្លាញ់ច្រើនជាងបុរស ដូច្នេះហើយក៏សារធាតុគីមីរលាយច្រើនជាងដូចជាផ្លាស្ទិច phthalate ជាដើម។ រាងកាយរបស់ស្ត្រីងាយនឹងប្រតិកម្មចំពោះ ជាតិពុលក្នុងដំណាក់កាលផ្សេងៗនៃជីវិតដូចជា៖ ពេលពេញវ័យ ពេលមានផ្ទៃពោះ ពេលម្តាយផលិតទឹកដោះ និងពេលឈប់មានរដូវ។

កំឡុងពេលមានផ្ទៃពោះ វាអាចមានផលវិបាកធ្ងន់ធ្ងរចំពោះទារកដែលមិនទាន់កើត។ សារធាតុគីមីដែលមានមុខងារស្រដៀងគ្នាចំពោះអរម៉ូនគឺជាបញ្ហាមួយដែលត្រូវបានដឹងថាជាការរំខានក្រពេញអង់ដូគ្រីន។ ដោយសារសុកមិនមែនជារបាំងការពារដែលមានសុវត្ថិភាព សមាសធាតុទាំងនេះអាចរំខានដល់ដំណាក់កាលលូតលាស់ទាំងអស់ក្នុងស្បូនដែលត្រូវបានគ្រប់គ្រងដោយអរម៉ូន។ នោះអាចនាំឱ្យខូចរូបរាងរបស់ទារកទើបនឹងកើតក៏ដូចជាជំងឺដែលច្រើនតែលេចឡើងនៅពេលក្រោយទៀត។

ការរំខានក្រពេញអង់ដូគ្រីនប៉ះពាល់ទាំងបុរសនិងស្ត្រីក្នុងកម្រិតដូចគ្នា។ អង្គការសុខភាពពិភពលោកសង្ស័យថានេះជាមូលហេតុនៃទម្រង់មហារីកដែលទាក់ទងនឹងអរម៉ូនគឺ មហារីកសុដន់ និងមហារីកពងស្វាស។ វាក៏ទំនងជាប៉ះពាល់ដល់ការមានកូននិងគុណភាពរបស់មេជីវិតឈ្មោលផងដែរ។ ការរំខានក្រពេញអង់ដូគ្រីន ក៏អាចបណ្តាលឲ្យធាត់ ជំងឺទឹកនោមផ្អែម ជំងឺរើម ការពេញវ័យមុនកំណត់ និងការខូចទ្រង់ទ្រាយនៃប្រដាប់បន្តពូជរបស់ខួរក្បាលដូចជាការក្រិនរ៉ូអ៊ុត (ការធ្វើតេស្ត៏មួយឬទាំងពីរពីពងស្វាស) និង

THE SECRET LIFE OF A SANITARY PAD
Life-cycle assessment of the energy and materials used in production




*Low-density polyethylene **Nitrogen oxides

**ការផលិតសំឡីអនាម័យរបស់ស្ត្រី វាមិនអាចអត់បាននូវការប្រើប្រាស់ផូស៊ីលជាវត្ថុធាតុដើម និងផ្លាស្ទីកនោះទេ។**




ស្ត្រីម្នាក់ដែលប្រើផលិតផលអនាម័យដែលអាចបោះបង់ចោលបានប្រឈមមុននឹងគ្រោះថ្នាក់ពីផ្លាស្ទិចអស់រយៈពេលជិតបួនទសវត្សរ៍មកហើយ។

ជំងឺ hypospadias (ការរំលោភបំពានលើក្រពេញទឹកនោមរបស់បុរស)។ ការកើនឡើងកាន់តែច្រើននៃចំនួនកុមារកំពុងដែលកើតមកហើយប្រឈមមុននឹងនឹងសារធាតុគ្រោះថ្នាក់ផ្សេងៗ។

ស្ត្រីប្រឈមមុខនឹងគ្រោះថ្នាក់នៃផ្លាស្ទិកនេះតាមរូបភាពផ្សេងៗគ្នាជាច្រើន។ មានកម្មករប្រមាណ ៣០ ភាគរយនៅក្នុងឧស្សាហកម្មផ្លាស្ទិកនៅទូទាំងពិភពលោកគឺជាស្ត្រី។ សម្ភារៈផ្លាស្ទិកដែលមានតម្លៃថោកអាចត្រូវបានផលិតក្នុងបរិមាណយ៉ាងច្រើនសម្រាប់ទីផ្សារពិភពលោក ហើយជាទូទៅស្ត្រីរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ធ្វើការក្នុង




ប៉ាតង់សម្រាប់ផលិតផលអនាម័យស្ត្រីបានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីចុងទសវត្សរ៍ ឆ្នាំ ១៩៩០។ មូលហេតុមួយគឺដោយសារតែ មានតំលៃថោក។

រោងចក្រផលិតកម្មឧស្សាហកម្មនេះ ដោយទទួលបានប្រាក់ឈ្នួលទាបហើយជាញឹកញាប់ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដោយមិនបានប្រើប្រាស់ឧបករណ៍ការការពារនោះ ទេ។ ការសិក្សារបស់ប្រទេសកាណាដាបានរកឃើញថា ស្ត្រីដែលធ្វើការងារជាមួយផ្លាស្ទិកនៅក្នុងឧស្សាហកម្មយានយន្តទំនងជាប្រឈមមុខនឹងជំងឺមហារីកសុដន់៥ដងច្រើនជាងគេ។

ផលិតផលអនាម័យរបស់មនុស្សស្រីក៏អាចបង្កឲ្យមានបញ្ហាផងដែរ សំឡីអនាម័យប្រភេទដងអាចមានផ្ទុកផ្លាស្ទិករហូតដល់ទៅ៦ភាគរយ ហើយសំឡីអនាម័យប្រភេទបន្ទះផ្ទុកប្រេងដែលមានប្រភពពីផ្លាស្ទិករហូតដល់ ៩០ ភាគរយ។ របស់ទាំងពីរនេះមានសមាសធាតុសកម្មនៃអរម៉ូន គឺ bisphenol A (BPA) និង bisphenol S (BPS)។ ឧបករណ៍សម្រាប់ប្រើសំឡីអនាម័យប្រភេទដងជាញឹកញាប់មានផ្ទុក phthalates ផងដែរ។ នៅសហរដ្ឋអាមេរិច ស្ត្រីម្នាក់អាចប្រើរបស់ទាំងនេះចន្លោះពី ១២.០០០ ទៅ ១៥,០០០ ក្នុងមួយជីវិតរបស់គាត់។ របស់ប្រើប្រាស់ជំនួសរួមមានដូចជា៖ ផលិតផលដែលអាចប្រើឡើងវិញនិងលាងសម្អាតព្រមទាំងពែងអនាម័យ។

នៅក្នុងតំបន់ក្រីក្រក្មេងស្រីជាច្រើនមិនអាចមានលទ្ធភាពប្រើប្រាស់របស់របរនាម័យបែបនេះទេ រឺក៏ថាផលិតផលទាំងនេះមិនមាននៅក្នុងប្រទេសតែម្តង។ នោះប្រហែលជាបង្ខំឱ្យក្មេងស្រីខកខានមិនបានទៅសាលារៀនរយៈពេលមធ្យម ៥ថ្ងៃកំឡុងពេលមករដូវជារៀងរាល់ខែ។ ផលិតផលដែលអាចប្រើឡើងវិញបាន មានតម្លៃថោក ហើយមានសុវត្ថិភាពជាងនេះអាចបំពេញភាពខ្វះខាតនេះបាន ហើយកាត់បន្ថយការបំពុលនិងកាកសំណល់ផងដែរ។ ភាគច្រើននៃឧបករណ៍ដែលប្រើតែមួយដងត្រូវបានបោះចោលនៅកន្លែងចាក់សម្រាម អាងស្តុកទឹក សមុទ្រ និងធ្វើឲ្យកកស្ទះប្រព័ន្ធបង្ហូរទឹកផងដែរ។

គ្រឿងសំអាងក៏អាចជាប្រភពនៃសារធាតុគ្រោះថ្នាក់ផងដែរ។ ១ភាគ៩ នៃស្ត្រីដែលនៅក្នុងបណ្តាប្រទេសឧស្សាហកម្មលោកខាងលិចប្រើប្រាស់គ្រឿងសំអាង១៥មុខផ្សេងគ្នាជារៀងរាល់ថ្ងៃ។ ហើយផលិតផលទាំងនេះមានផ្ទុកសារធាតុគីមីរហូតដល់ទៅ ១០០ ប្រភេទ ដែលមានខ្លះជាសារធាតុគីមីដែលមានគ្រោះថ្នាក់ដល់សុខភាព។ គ្រឿងសំអាងជាច្រើនមានផ្ទុកនូវមីក្រូផ្លាស្ទិកជ្រាបទៅក្នុងសុកហើយចូលទៅក្នុងគតិតែម្តង។

ចុងក្រោយស្ត្រីនៅតែជាអ្នកទទួលខុសត្រូវក្នុងការធ្វើការងារផ្ទះ ឬក៏ធ្វើការជាអ្នកបោសសំអាត។ ផលិតផលបោសសំអាតក៏មានផ្ទុកមីក្រូផ្លាស្ទិក និងសារធាតុដែលបង្កអន្តរាយដូចជា៖ សារធាតុ surfactants និងសារធាតុរំលាយ។ ការជ្រើសរើសផលិតផលឱ្យកាន់តែប្រុងប្រយ័ត្ន និងការប្រើប្រាស់វត្ថុធាតុដើមដែលមិនប៉ះពាល់ដល់បរិស្ថាន ឬសម្ភារៈសាមញ្ញដូចជា៖សាប៊ូដុំទន់ៗ និងអាស៊ីតស៊ីទ្រី អាចកាត់បន្ថយបន្ទុកមកលើទាំងមនុស្សនិងបរិស្ថាន។ ប៉ុន្តែជម្រើសបែបនេះរបស់អតិថិជន មិនបានធ្វើឱ្យក្រុមហ៊ុនផលិតអាចគេចផុតពីការទទួលខុសត្រូវចំពោះការស្វែងរកអ្វីផ្សេងមកជំនួសគ្រឿងផ្សំនិង វត្ថុធាតុដើមដែលអាចបង្កគ្រោះថ្នាក់បាននោះឡើយ។

នៅពេលដែលកាកសំណល់ត្រូវបាននាំចេញទៅប្រទេសកំពុងអភិវឌ្ឍន៍ ទីកន្លែងចាក់សំរាមបានប្រែក្លាយជាប្រភពចំណូលដ៏សំខាន់សម្រាប់អ្នកក្រ។ អ្នករើសសំរាមរាប់លាននាក់នៅជុំវិញពិភពលោកដែលភាគច្រើនជាស្ត្រីនិងកុមារដែលមកពីគ្រួសារមានជីវភាពក្រីក្របំផុតនៅក្នុងសង្គម ដើររើសសំរាមផ្លាស្ទិកដែលអាចកែច្នៃឡើងវិញបាន និងកាកសំណល់អគ្គិសនីនៅទីកន្លែងចាក់សំរាម។ ភាគច្រើនទីតាំងដែលជាតិពុលខ្ពស់បែបនេះ បានក្លាយជាប្រភពចំណូលគ្រួសារតែមួយគត់របស់ពួកគាត់។ ដើម្បីទទួលបានស្ពាន់ដ៏មានតម្លៃ គេត្រូវដុតខ្សែកាបដែលមានជ័ររុំពីក្រៅចេញសិន។ ផ្សែងទាំងនេះមានផ្ទុកសារធាតុឌីអុកស៊ីតពុលខ្ពស់ដែលបង្កគ្រោះថ្នាក់ដល់ការបន្តពូជ ប៉ះពាល់

ទារក និងអាចបណ្ដាលឱ្យកើតជំងឺមហារីកទៀតផង។ វាកើតឡើងជាពិសេសចំពោះស្ត្រីដែលដុតសំរាមតាមផ្ទះ ឬជាអ្នកប្រឈមមុខជាមួយកាកសំណល់ដែលមានជាតិពុលទាំងនេះ។

ចំណេះដឹងអំពីគ្រោះថ្នាក់ដែលបណ្ដាលមកពីផ្លាស្ទីកមិនត្រូវបានផ្សព្វផ្សាយពាសពេញពិភពលោកនោះឡើយ ស្ត្រីគឺជាក្រុមគោលដៅសំខាន់បំផុតនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យមានការផ្លាស់ប្ដូរជាមូលដ្ឋាននៃឥរិយាបថ និងការអនុវត្តប្រចាំថ្ងៃ ក៏ដូចជាក្នុងការទាមទារឱ្យមានសកម្មភាពនយោបាយសម្រាប់ការការពារកាន់ប្រសើរជាងមុន។ ជារឿយៗ ស្ត្រីមានប្រតិកម្មចំពោះគ្រោះថ្នាក់ផ្សេងៗលឿងជាងបុរស ហើយពួកគេមិនសូវបានត្រៀមខ្លួនក្នុងការធ្វើឱ្យមនុស្សនិងភពលោកគ្រោះថ្នាក់នោះទេ។ នោះជាការពិតតាមរយៈ តួនាទីរបស់ពួកគេ ទាំងក្នុងនាមជាសហគ្រិន អ្នកប្រើប្រាស់ និងអ្នកគ្រប់គ្រងគ្រួសាររបស់ពួកគេ។ មានភស្តុតាងជាច្រើនបង្ហាញថាទង្វើររបស់ពួកគេគិតបរិស្ថានច្រើនជាងបុរស។ គំនិតផ្ដួចផ្ដើមដែលមានគោលបំណងកាត់បន្ថយការប្រើប្រាស់ផ្លាស្ទីក និងការពារប្រជាជន និងបរិស្ថានពីការបំពុលបរិស្ថានត្រូវបានចាប់ផ្ដើមដោយស្ត្រី។ ពួកគេសមនឹងទទួលបានឋានៈស្មើគ្នានៅក្នុងនយោបាយ ជំនួញគ្រួសារ និងសហគមន៍ ដើម្បីឲ្យពួកគេអាចចូលរួមកាន់តែច្រើនក្នុងការបង្កើតសង្គមនិងបរិស្ថានមួយដែលគ្មានជាតិផ្លាស្ទីកនិងជាតិពុល។

# ចំណីអាហារដ៏ឆ្ងាញ់ពិសារ

**ឧស្សាហកម្មម្ហូបអាហារគឺជាអ្នកប្រើប្រាស់ផ្លាស្ទិកច្រើនជាងគេ។ ជ័រនិងស្នោត្រូវបានប្រើប្រាស់ដើម្បីការពារចំណីអាហារពីការខូចខាត រក្សាឱ្យស្រស់ និងធ្វើឱ្យវាមើលទៅគួរឱ្យចាប់អារម្មណ៍។ ប៉ុន្តែភាពស្រស់ស្អាតក៏មានតម្លៃមួយដែរ ផ្លាស្ទិកត្រូវបានបោះចោលទៅលើដី ហើយជ្រាបចូលទៅក្នុងប្រព័ន្ធចំណីអាហាររបស់យើង។**

ផ្លែត្រសក់ត្រូវបានវេចខ្ចប់នៅក្នុងប៉ូលីថែន បន្លែសាលាដត្រូវបានកាត់រៀបចំទុកទទួលទានយ៉ាងល្អនៅក្នុងចានជ័រដែលអាចប្រើហើយបោះចោលបាន អាហារត្រូវបានរៀបចំតាមទំហំផ្សេងៗគ្នា ធ្នើនីមួយៗនៅផ្សារទំនើបផ្ទុកទៅដោយអាហាររុំផ្លាស្ទិកជាច្រើន។ ផ្លាស្ទិកដើរតួនាទីយ៉ាងសំខាន់នៅពេលដែលទីផ្សារចំណីអាហារ ត្រូវបានផ្លាស់ប្តូរពីតូបក្នុងផ្សារធម្មតា ចូលទៅក្នុងទីផ្សារទំនើបដែលមានការផ្គត់ផ្គង់អាហារកែច្នៃយ៉ាងសំបូរបែបហើយមានប្រភពមកពីពាសពេញពិភពលោក។

ផ្សារទំនើបតែងតែលក់គ្រឿងទេសដដែលៗពេញមួយឆ្នាំមិនថាជាមកពីតំបន់ណាក៏ដោយ។ ការវេចខ្ចប់ធានាថារបស់របរនៅតែស្រស់ហើយអាចដឹកជញ្ជូនទៅទីកន្លែងឆ្ងាយៗបាន។ លើសពីនេះទៀត អ្នកប្រើប្រាស់ជាច្រើន

**មានការសិក្សាតិចតួចបំផុតនិយាយអំពីបរិមាណផ្លាស្ទិកនៅក្នុងដី។ ប៉ុន្តែការចម្លងរោគដីត្រូវបានគេគិតថានៅរវាងពី ៤ ទៅ ២៣ ដងខ្ពស់ជាងនៅក្នុងសមុទ្រ។**






នៅក្នុងប្រទេសអភិវឌ្ឍន៍ចង់មានលទ្ធភាពរៀបចំម្ហូបអាហារបានលឿនរហ័ស ជារៀងរាល់ថ្ងៃភាពងាយស្រួលឈរនៅក្នុងលំដាប់ដំបូង។ ការស្រាវជ្រាវនៅប្រទេសអាឡឺម៉ង់នៅឆ្នាំ ២០១៩ បានរកឃើញថាប្រជាជនចំនួន ៩៨ ភាគរយគិតថាវាសំខាន់ណាស់ដែលអាចរៀបចំអាហារបានរហ័សនិងងាយស្រួល។ ឧស្សាហកម្មម្ហូបអាហារឆ្លើយតបទៅនឹងតម្រូវការនេះតាមរយៈការផ្តល់ជូននូវផលិតផលដែលត្រូវបានរៀបចំនិងចំអិនទុករួចជាស្រេច ហើយវេចខ្ចប់ដោយផ្លាស្ទីក។

មនុស្សកាន់តែច្រើននៅជុំវិញពិភពលោកឥឡូវនេះរស់ក្នុងក្រុងតែម្នាក់ឯង។ ហើយទម្លាប់នៃការបរិភោគរបស់មនុស្សដែលមាននៅថ្នាក់កណ្តាលក៏កំពុងតែផ្លាស់ប្តូរដែរ។ និន្នាការទាំងនេះជួយជំរុញឲ្យចំណែកទីផ្សារនៃផ្សារទំនើបក៏ដូចជាឧស្សាហកម្មផ្លាស្ទីកមានការកើនឡើងផងដែរ។ បរិមាណនៃការវេចខ្ចប់ ដែលប្រើក្នុងឧស្សាហកម្មម្ហូប

ដបទឹកត្រូវបានគេផ្សព្វផ្សាយថាជាជម្រើសសម្រាប់សុខភាពជំនួសឱ្យទឹកចេញពីរ៉ូប៊ីនេ។ អ្នកផលិតដបទឹកទាំងនោះបង្ហាញតែធាតុផ្សំជារ៉ែផ្សេងៗ តែមិនបានបង្ហាញពីភាគល្អិតរបស់ផ្លាស្ទីកទេ។




Microplastic particles that sewage-treatment plants cannot separate out are sprayed onto fields with the residual sludge commonly used as a fertilizer.

អាហារបាននិងកំពុងកើនឡើងជាច្រើនឆ្នាំមកហើយ។ បើយោងតាមGrand View Research ដែលជាអង្គការអាមេរិកបានប៉ាន់ប្រមាណតម្លៃទីផ្សារនៃឧស្សាហកម្មវេចខ្ចប់ចំណីអាហារមានចំនួន ២៧៧,៩ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៧ ហើយត្រូវបានព្យាករណ៍នឹងមានកំណើនជាង៥ ភាគរយសម្រាប់ឆ្នាំ ២០១៨។ និន្នាការនៅទ្វីបអឺរ៉ុបក៏ស្រដៀងគ្នាខ្លាំងណាស់ដែរគឺថានៅឆ្នាំ២០១៨ ឧស្សាហកម្មនេះបានគេប្រើការវេចខ្ចប់ជាង១,១៣កោដ។ ជាទូទៅប្រភេទនៃការវេចខ្ចប់គឺផ្លាស្ទីក។ ការវិភាគដោយវិទ្យាស្ថានគោលនយោបាយបរិស្ថានអឺរ៉ុបបានគាំទ្រដល់ការរកឃើញទាំងនេះថា សំរាមផ្លាស្ទីកភាគច្រើននៅមហាសមុទ្រគឺជាកាកសំណល់នៃការវេចខ្ចប់អាហារ។

ប៉ុន្តែការវេចខ្ចប់មិនមែនជាមូលហេតុតែមួយនោះទេ។ កសិកម្មគឺជាអ្នកប្រើប្រាស់ផ្លាស្ទីកធំលំដាប់ទី ៦ នៅអឺរ៉ុប ហើយនៅទូទាំងពិភពលោកប្រើប្រាស់វត្ថុធាតុដើមប្រមាណ ៦.៥ លានតោនជារៀងរាល់ឆ្នាំ។ ផលិតកម្មផ្លែឈើ និងបន្លែហាក់ដូចជាមិនអាចទៅរួចបានទេបើគ្មានផ្លាស្ទីក៖ ប្រព័ន្ធធារាសាស្ត្រ ផ្ទះកញ្ចក់ និងប៉ូលីថានណៃលសុទ្ធតែផលិតចេញពីផ្លាស្ទីក។ សំណាញ់ផ្លាស្ទីកអាចការពារផ្លែនិងរុក្ខជាតិផ្សេងៗពីពពួកសត្វ បក្សីបាន។ ផ្ទៃដីដាំដុះទាំងមូលត្រូវបានគ្របដណ្តប់ដោយបន្ទះផ្លាស្ទីកដើម្បីរក្សាកំដៅដីក្តៅនិងពន្យាពេលរដូវដាំដុះ ឧទាហរណ៍ការធ្វើឱ្យប្រមូលផលមើមដំឡូងបានលឿនជាងមុន។

ការជជែកវែកញែកគឺទើបតែត្រូវបានចាប់ផ្តើមពិភាក្សាពីមីក្រូផ្លាស្ទីកនៅក្នុងដី សត្វចិញ្ចឹមនិងនៅក្នុងចំណីអាហាររបស់យើងប៉ុណ្ណោះ។ ការស្រាវជ្រាវដែលពាក់ព័ន្ធតិចតួចណាស់ត្រូវបានធ្វើទៅលើការខូចខាតចំពោះដីដែលបណ្តាលមកដោយផ្លាស្ទីកនិង មីក្រូផ្លាស្ទីក។




Denmark
Hong Kong
New Zealand
Switzerland
Germany
Austria
Malaysia
India
Norway
Japan
China
Philippines
Vietnam
0
5
20000
40000
60000
80000

